**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ១៩៣ប្រ
ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២
**សាលដីកា**
លេខៈ៣៣
ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក .............. ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ................ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

-លោក ............

**តំណាងមហាអយ្យការ**

-ឯកឧត្តម ............ ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៣៦"ច" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៤៥ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍

រវាងដើមចោទឈ្មោះខពភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើការនៅក្រសួងវប្បធម៌ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១៥១ ផ្លូវលេខ១៦៣ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ មានមេធាវីកញ្ញា .......... ។ ចុងចម្លើយឈ្មោះងធ ភេទប្រុសអាយុ៥៤ឆ្នាំ ជាតិខ្មែរទីលំនៅ ផ្ទះលេខ១៣ ផ្លូវ៣៤៨ សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

**<u>កម្មវត្ថុបណ្តឹងៈ</u>** ប្តឹងលើដីកាសម្រេចកិច្ចការប្រញាប់លេខ០២ប្រ ចុះថ្ងៃទី០៤-០១-២០០២

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៩៣ប្រ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០០២ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ១៣០ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ របស់ឈ្មោះ.......... មិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ៣៦"ច" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះខពបានប្តឹងសុំផ្អាក និងជំទាស់សាលក្រមរដ្ឋប្បវេណីលេខ៦១"ខ" ចុះថ្ងៃទី១៤-៦-២០០១ របស់តុលាការក្រុង ភ្នំពេញ ។ កន្លងមកឈ្មោះជធបានប្តឹងពីសសថទាមទារប្រាក់ទៅតុលាការ ។ ដើម្បីធានាសំណងជធបានប្តឹងសុំកិច្ចការប្រញាប់ឃាត់តូបលេខ៣៣១ បេ១ ផ្សារអូឡាំពិក របស់ឈ្មោះសសថទុកជាបណ្តោះអាសន្ន ដើម្បីលក់ធានាសំណងឱ្យឈ្មោះ ជធ។ក្នុងរយៈពេលតុលាការចេញដីកាសម្រេចកិច្ចការប្រញាប់ឃាត់នេះខ្លួនក៏បានដាក់ពាក្យបណ្តឹងចូលតុលាការឃាត់ទ្រព្យអ្នកដទៃ ព្រោះតូបលេខ៣៣១ បេ១ នៅផ្សារអូឡាំពិកឈ្មោះសសថបានលក់ឱ្យខ្លួនរួចហើយ នៅថ្ងៃទី១១-៨-២០០០ និងលិខិតផ្ទេរកម្មសិទ្ធិតូបនេះ ចុះថ្ងៃទី១២-៨- ២០០០ រួចស្រេចហើយ

ក្នុងនោះរាល់លិខិតទាំងពីរ ក៏មានគណៈកម្មការផ្សារអូឡាំពិក បានឃើញនិងចូលរួមក្នុងការទិញលក់នេះដែរ ។ ដូច្នេះ តុលាការមិនអាចលក់ឡាយឡុងនូវតូប ដែលមានលេខដូចខាងលើយកប្រាក់មកសងជធបានឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦១"ខ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលបានសម្រេចដូចតទៅ :

១-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១២-៣-២០០១ របស់ឈ្មោះតាំង អ៊ីម ឈ្មោះ ជា ចាន់ធី និងឈ្មោះមៀវ ស៊ាន ទៅឱ្យឈ្មោះជធជាតំណាងទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១២-០៣-២០០១ របស់ឈ្មោះជធទុកជាត្រឹមត្រូវតាមទម្រង់ និគតិច្បាប់ ។

៣-បង្គាប់ឱ្យឈ្មោះសសថសងប្រាក់ជំពាក់ថ្លៃទិញសារ៉ុង និងក្រណាត់,ចំនួន១៥.៧០០ ដុល្លាអាមេរិក ទៅឱ្យឈ្មោះជធជាតំណាងឱ្យឈ្មោះតាំង អ៊ីម ឈ្មោះជា ចាន់ធី និងឈ្មោះមៀវ ស៊ាន ។

៤-បើឈ្មោះសសថពុំមានប្រាក់សងគ្រប់ចំនួនទេ ត្រូវរឹបអូសតូបលេខ៣៣១ បេ១ នៅផ្សារអូឡាំពិក លក់ឡាយឡុងដើម្បីជានាសំណង បើសងពុំគ្រប់ត្រូវរឹបអូសទ្រព្យសម្បត្តិដទៃទៀត ជាកម្មសិទ្ធិរបស់ឈ្មោះសសថលក់ឡាយឡុង សងរហូតគ្រប់ចំនួន១៥៧០០ ដុល្លា ។

៥-បង្គាប់ឱ្យឈ្មោះសសថបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ និងរង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥.០០០៛ សរុបចំនួន៧.០០០៛ ប្រាក់នេះកាត់យកពីប្រាំកំចំនួន ៧.០០០៛ ដែលដើមចោទបានបង់រួចហើយ កាលបើផុតកំណត់បណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះសសថសងប្រាក់ចំនួន ៧.០០០៛ ទៅដើមចោទវិញ និងឲ្យបង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ចំនួន១៥.៧០០ ដុល្លា ត្រូវជា១៥៧ ដុល្លា ហើយប្រាក់នេះ ត្រូវបង់ចូលថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៦-សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទឈ្មោះជធកំបាំងមុខចុងចម្លើយឈ្មោះ សសថបើកផ្លូវប្តឹងទាស់ក្នុងកំណត់ច្បាប់ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០២ ប្រក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ សម្រេចសេចក្តីដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់មេធាវី.......... ចុះថ្ងៃទី២៧-១១-២០០១ តំណាងឈ្មោះខពទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយ ផ្ទុយនឹងគតិច្បាប់ ។

២-អនុញ្ញាតឱ្យអ្នកអនុវត្តសាលក្រមបន្តការអនុវត្តន៍សាលក្រមលេខ៦១"ខ" ចុះថ្ងៃទី១៤-៦-២០០១ តាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៤០០០៛ របស់ដើមចោទដាក់ថវិការដ្ឋ និងចំណាយផ្សេងៗ ។

៤-ដីកានេះ សម្រេចសេចក្តី និងប្រកាសជាសាធារណៈចំពោះមុខមេធាវី.......... តំណាងខពនិងចំពោះមុខ ជធចុងចម្លើយ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

៥-ដីកានេះ មានអានុភាពអនុវត្តន៍ភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០១"ក" ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះ.......... មិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ០២ ប្រក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការជ្មប្បវេណីលេខ៣៦"ច" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ បានសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤-០១-២០០២ របស់មេធាវី .......... ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចកិច្ចការប្រញាប់លេខ០២ប្រ"ក" ចុះថ្ងៃទី០៤-០១-២០០២ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើកិច្ចការដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ១៣០ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០០២ របស់មេធាវីអ្នកស្រី.......... មិនសុខចិត្តនឹងសាលដីការជ្មប្បវេណីលេខ៣៦"ច" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍គ្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០០២ របស់ឈ្មោះ ខព។

បានឃើញសារណាតបចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះដធ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សាលដីកាសាលាឧទ្ធរណ៍ បានសម្រេចត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះខពនាពេលសវនាការថា៖ តូបនេះឈ្មោះសសថនិងប្ដី បានលក់ឱ្យខ្ញុំនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០០ ។ ខ្ញុំដឹងអ្នកទិញតូបនេះត្រូវបង់ប្រាក់ប្រចាំខែ និងឈ្នួលផ្សារ តូបនេះក្រោយពីទិញ ខ្ញុំបានជួលឱ្យឈ្មោះសសថ១ខែ១២០$ ពេលទិញតូបនេះហើយ ខ្ញុំមិនបានគ្រប់គ្រងទេ ទុកជួល ។ តាមពិតច្បាប់ក្នុងផ្សារគ្រាន់តែទិញសិទ្ធិក្នុងរយៈពេល១៥ឆ្នាំ ប៉ុណ្ណោះ ប្រាក់ឈ្នួលផ្សេងៗគឺ សសថជាអ្នកបង់រហូតមកដល់ថ្ងៃគេចខ្លួនបាត់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះដធនាពេលសវនាការថា៖ តូបនេះសសថទិញឥវ៉ាន់ខ្ញុំ ជំពាក់លុយមិនព្រមសង ខ្ញុំប្ដឹងគណៈកម្មការផ្សារក៏បិទ តូបនោះទៅ ដោយខ្លាចក្រុមហ៊ុនយកតូបវិញ ខ្ញុំប្ដឹងដល់តុលាការហូតសាលក្រមចូលស្ថាពរទើបដើមចោទមកប្ដឹងទាស់ ពេលចរចាគ្នានៅតុលាការក្រុង ខ្ញុំថា បើដើមចោទមានលទ្ធភាពបើកតូបវិញបាន ខ្ញុំឱ្យលុយ ២០០០$ តែខឹម ពិនគាត់ធ្វើមិនបាន ក្រោយមកតំណាងក្រុមហ៊ុនបានតម្រូវឱ្យខ្ញុំបង់យកតូបនេះ ដោយបានបំពេញត្រឹមត្រូវតាមលក្ខខ័ណ្ឌក្រុមហ៊ុន ព្រោះតំណាងក្រុមហ៊ុនថា បើខ្ញុំមិនបង់ទេក្រុមហ៊ុន និងយកហើយ តាមច្បាប់ការផ្ទេរលក់តូប លុះណាមានខណ្ឌដឹងឮ តែឯកសារខពធ្វើមិនបានត្រឹមត្រូវទេ ហេតុនេះ ក៏មិនអាចយកជាការបានដែរ ព្រោះក្រុមហ៊ុនក៏មិនបានដឹង សូមតុលាការមេត្តាតម្កល់សេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយដោះសារបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៣០ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ របស់កញ្ញាឆយ ល្លី មេធាវីលោកខឹម ពិត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលលោកខពលើកឡើងក្នុងសារណា ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ របស់លោកថា លោកបានទិញតូបទំនាស់លេខ៣៣១ បេ១ ពីម្ចាស់ឈ្មោះសសថតាំងពីថ្ងៃទី១២-៨-២០០០ និងបានផ្ទេរសិទ្ធិគ្រប់គ្រង តាមលិខិតចុះថ្ងៃទី១២-៨-២០០០ ដោយមានលោកប៉ា ប៊ុណ្ណា ជាគណៈកម្មការផ្សារចុះហត្ថលេខាដឹងឮផង ដែលគប្បីតុលាការត្រូវផ្អាកការអនុវត្តសាលក្រមលេខ៦១"ខ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០១ រង់ចាំរកឱ្យឃើញម្ចាស់តូបពិត ប្រាកដមែននោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា៖

-តាមលិខិតលេខ៣២ ០១.ធ.ត ចុះថ្ងៃទី៣១-៥-២០០១ របស់គណៈកម្មការផ្សារអូឡាំពិក ចុះហត្ថលេខា ដោយលោកប៉ា ប៊ុណ្ណា ដដែល បានបញ្ជាក់ថា តូបលេខ៣៣១ បេ១ ពិតជាកម្មសិទ្ធិរបស់ឈ្មោះសសថតាំងពីឆ្នាំ១៩៩៤ រហូតដល់បច្ចុប្បន្ននេះ ។

-តាំងពីថ្ងៃទី ១២-៨-២០០០ ដែលលោកខឹម ពិនអះអាងថា ខ្លួនបានទិញតូប២ពីឈ្មោះសសថរហូតដល់ថ្ងៃមានទំនាស់ថ្ងៃទី២២-៣-២០០១ លោកពុំដែលបានបង់ថ្លៃឈ្នួល ដែលតាមប្រការ៣ នៃកិច្ចសន្យាជួលតូបចុះថ្ងៃទី៣០-០៦-៩៤ កាលណាមិនបានបង់ថ្លៃលលើសពី១៥ថ្ងៃ កិច្ចសន្យាជួលត្រូវទុកជាមោឃៈ បានន័យថាការដែលលោកខពមិនបាន បង់ថ្លៃឈ្នួល់តូបសោះនោះ លោកពុំមានសិទ្ធិតាមកិច្ចសន្យាជួលទៀតទេ ។ ផ្ទុយទៅវិញ លោកជធបានបង់ថ្លៃឈ្នួលតូបនេះជាប់រហូតដល់បច្ចុប្បន្ន ។

-យល់ឃើញថា ការដែលលោកខពលើកឡើងនាពេលសវនាការនេះថា ក្រោយពេលទិញតូបលេខ៣៣១ បេ១ហើយ លោកបានជួលបន្តឱ្យអ្នកស្រីសសថវិញនោះ ពុំមានភស្តុតាងគួរឱ្យជឿបានទេ ។

-យល់ឃើញថាលិខិតកិច្ចសន្យាលក់តូប ចុះថ្ងៃទី១១-៨-២០០០ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០០ រវាងអ្នកស្រីសសថជាមួយលោកខពពុំមានសុពលភាពអាចយកជាការបានទេ ពីព្រោះតាមកិច្ចសន្យាជួលតូប ការផ្ទេរសិទ្ធិអាចយកជាការបាន លុះត្រាតែមានការ យល់ព្រមពីអាជ្ញាធរខណ្ឌចំការមន ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៣៦"ច" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ១៣០ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ របស់កញ្ញា.......... មេធាវីលោកខពទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹង គតិច្បាប់

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៣៦"ច" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោកជធបានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្មឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យលោកខពសងប្រាក់ចំនួន ១៥.០០០៛ នេះទៅលោកជជវិញ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣